ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្ដាល
ស្រុកអង្គស្នួល ឃុំម្កាក់

# សេចក្ដីអំពាវនាវ

អាត្មាភាព ខ្ញុំព្រះករុណា ទូលព្រះបង្គំ ខ្ញុំបាទ ជាព្រះចៅអធិការ គណកម្មការ លោកអាចារ្យ ពុទ្ធបរិស័ទ វត្តស្រះមុជ្ជលិន្ទ ហៅកោះគ្រើង ស្ថិតក្នុងឃុំម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល

សូមចំរើនពរ និងគោរពចំពោះសន្ដានទឹកចិត្តសាធុសប្បុរសគ្រប់មជ្ឈដ្ឋាន មេត្តាចូលរួមចំណែកឧបត្ថម្ភដល់ការកសាងព្រះសុវណ្ណចេតិយតម្កល់នូវព្រះបរមសារីរិកធាតុព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ប្រយោជន៍បានជាទីគោរពបូជា ធ្វើអញ្ជលីកម្មចំរើនទៅដោយបុណ្យកុសលទាំងមនុស្ស និងទេវតាទាំងឡាយ។

ព្រះសុវណ្ណចេតិយបានបញ្ចុះបឋមសិលាកាលពីថ្ងៃទី ១៣ ឧសភា ២០១៣ ក្រោមអធិបតីភាពលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស អាជ្ញាធរឃុំ ស្រុក ដែលបានអនុញ្ញាតអោយសាងសង់អំពីបេតុងទំហំ ៨ម ពិដាន ២ជាន់ កំពស់ ២៥ម រចនាដោយគ្រឿងក្បាច់ លាបពណ៌ទឹកមាស លើតម្លៃសរុប ១២០,000$ (ដប់ពីរម៉ឺនដុល្លារសហរដ្ឋអាមេរិក) ទាំងសម្ភារៈ។

មកដល់សព្វថ្ងៃនេះ បានរៀបខឿន និងចាក់ដីរួចរាល់ហើយ តែពុំមានលទ្ធភាពសាងសង់តួព្រះចេតិយទើបយើងខ្ញុំទាំងអស់គ្នាសូមនិមន្ត យាង អញ្ជើញ សម្ដេច ទ្រង់ ឯកឧត្តម អ្នកឧកញ្ញា លោក លោកស្រី សាធុសប្បុរសទាំងអស់ សូមមេត្តាបរិច្ចាគធនធានជួយឧបត្ថម្ភ តាមសទ្ធាជ្រះថ្លា ដើម្បីបូជាព្រះគុណ ព្រះសម្មាសម្ពុទ្ធ និងទុកជាកំណប់ទ្រព្យក្នុងព្រះពុទ្ធសាសនាផង ទុកជាសម្បត្តិរបស់ជាតិយើងផង។

ហេតុនេះសូមសាធុសប្បុរសទាំងអស់ មេត្តាចូលរួមឧបត្ថម្ភដល់ការកសាង និងទទួលនូវការគោរពកោតក្រែងយ៉ាងជ្រាលជ្រៅអំពីយើងខ្ញុំ ដោយសេចក្ដីអនុគ្រោះ។

សូមចំរើនពរ និងជូនពរ សូមអោយមានពន្លឺភ្លឺស្វាងដោយសទ្ធា និងបញ្ញា សូមអោយឆាប់បានសម្រេចឧត្តមធម៌ មគ្គផលព្រះនិព្វានតាមកាលដ៏សមគួរ។ សូមអនុមោទនាបុណ្យ!

ការចូលរួមចំណែករបស់សាធុសប្បុរស គឺជាមហាកុសលប្រកបដោយសទ្ធា និងបញ្ញា ម្យ៉ាងទៀត គឺជាមហាកិត្តិយសដ៏ឧត្តមសម្រាប់វត្តស្រះមុជ្ជលិន្ទយើងខ្ញុំ។

ទំនាក់ទំនងទូរស័ព្ទ: 089 944 945 092 657 656 092 87 97 57

សូមអរព្រះគុណ និងសូមអរគុណ

ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៣

| ព្រះចៅអធិការ | អគ្គទីប្រឹក្សា | លោកអាចារ្យ | គណកម្មការ |
|---|---|---|---|
| ធីប្បញ្ញោ អ៊ុន ប្រាក់ | ជា ចណ្ណាឫទ្ធិ | ភាក់ ភន | លុយ សួន |